ក្រសួងសុខាភិបាល

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

៚✱៛

# សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងសុខាភិបាល
# ស្តីពី
# ការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រងកម្មវិធីចាក់វ៉ាក់សាំងកូវីដ ១៩

គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ មានកិត្តិយស សូមជម្រាបជូនសាធារណជនទាំងអស់ មេត្តាជ្រាបថា ក្រសួងសុខាភិបាលបានបង្កើតកម្មវិធី (Application) ឈ្មោះថា KhmerVacc សម្រាប់កត់ត្រា និងគ្រប់គ្រងព័ត៌មាននៃការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ របស់ប្រជាពលរដ្ឋ ដែលនឹងដាក់ឱ្យប្រើប្រាស់ជាសាធារណៈចាប់ពី ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២១ តទៅ។ អំឡុងពេលរង់ចាំការសម្រេចដាក់ឱ្យប្រើប្រាស់កម្មវិធី KhmerVacc ពីក្រុមហ៊ុន Google និងក្រុមហ៊ុន Apple លើ Play Store និង App Store ជាបណ្ដោះអាសន្នលោកអ្នកអាចទាញយកកម្មវិធី KhmerVacc មកប្រើប្រាស់តាមរយៈគេហទំព័រ https://cambodia-vaccine.gov.kh។ ដើម្បីចូលប្រើកម្មវិធី KhmerVacc សូមអនុវត្តតាមការណែនាំដូចខាងក្រោម៖

- ចូលក្នុងគេហទំព័រ https://cambodia-vaccine.gov.kh/vcc/vaccine_app.apk ឬស្កេន QR Code ដើម្បីទាញមកប្រើប្រាស់ (Download) លើ Mobile App (អាចដំណើរការលើប្រព័ន្ធ Android) ដែលមានឈ្មោះ KhmerVacc
- ចុចកន្លែង **"ចុះឈ្មោះថ្មី"** បំពេញព័ត៌មានតាមការតម្រូវរបស់ប្រព័ន្ធ បន្ទាប់មកចុចកន្លែង **"បង្កើតឈ្មោះចូល"** ដើម្បីបង្កើតគណនីប្រើប្រាស់ ដោយកំណត់ឈ្មោះ និងលេខសំងាត់ផ្ទាល់ខ្លួនរបស់លោកអ្នក រួចចុចកន្លែង **"បញ្ជូន"** ជាការស្រេច។
- លោកអ្នកអាចពិនិត្យព័ត៌មានដែលបានចុះឈ្មោះ ដោយជ្រើសរើសកម្មវិធី KhmerVacc រួចបញ្ចូលឈ្មោះ និងលេខសំងាត់ដែលបានបង្កើត រួចចុចកន្លែង **"ចូល"** នោះលោកអ្នក នឹងឃើញព័ត៌មានផ្ទាល់ខ្លួនដែលបានចុះឈ្មោះ។
- បន្ទាប់ពីការចុះឈ្មោះទទួលបានជោគជ័យ ក្រសួងសុខាភិបាល នឹងជូនដំណឹងអំពីពេលវេលា និងទីកន្លែងត្រូវចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ តាមរយៈសារ (Notification App) ទៅតាមពេលវេលាសមស្រប។

សូមសាធារណជនទាំងអស់ដែលស្ម័គ្រចិត្តចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ មេត្តាចុះឈ្មោះជាមុនតាមរយៈ **កម្មវិធីចាក់វ៉ាក់សាំង** KhmerVacc។ ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកខ្សែទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ។

ថ្ងៃពុធ ០៤ រោច ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ,ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងជាប្រធាន**

**គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ ១៩**

**ម៉ម ប៊ុនហេង**

KhmerVacc

ព្រះរាជាណាចក្រកម្ពុជា

KINGDOM OF CAMBODIA

# កម្មវិធីចាក់វ៉ាក់សាំងខ្មែរ

VACCINATION MOBILE APPLICATION




## ចូលក្នុងកម្មវិធី

ឈ្មោះអ្នកប្រើប្រាស់

ពាក្យសម្ងាត់

ភ្លេចឈ្មោះអ្នកប្រើឬពាក្យសម្ងាត់

ចូល

ចុះឈ្មោះថ្មី

រក្សាសិទ្ធិដោយក្រសួងសុខាភិបាល